ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

27/3

## តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងរដ្ឋប្បវេណី

## សាលាឧទ្ធរណ៍ភ្នំពេញ

លេខ:២០២

ចុះថ្ងៃទី៣០-៥-១២

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣

សាលដីកា

លេខ:០៥"ក្រVIញ"

ចុះថ្ងៃទី២១-០២-២០១៣

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### ក្រឡាបញ្ជី

លោក [redacted]

-ដើមចោទឈ្មោះ: [redacted] សុជាតា ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

-ចុងចម្លើយឈ្មោះ: [redacted] សំអៀន ហៅ ចូច ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិសែសិន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

-មានមេធាវី [redacted] តំណាងដោយអាណាត្តិឲ្យចុងចម្លើយ

អំពីរឿង: ប្ដឹងទាមទារប្រាក់

### អំពីអង្គហេតុ និងចំណុចវិវាទ

នៅខែកញ្ញា ឆ្នាំ២០១១ ចុងចម្លើយបានទទួលធ្វើដំបូលផ្ទះរបស់ដើមចោទ ប្រក់ក្បឿង ភីប៉ារ៉ូស៊ីម៉ង់ នៅពេលធ្វើដំណើរការប្រក់ដំបូល កូនជាងរបស់ចុងចម្លើយធ្វើឲ្យខូចខាតក្បឿងរបស់ដើមចោទ។ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ ចុងចម្លើយបានធ្វើកិច្ចសន្យាថា នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ គាត់សងប្រាក់ឲ្យដើមចោទគ្រប់ចំនួន។ លុះដល់ថ្ងៃកំណត់សងប្រាក់មកដល់ ចុងចម្លើយមិនព្រមសងប្រាក់តាមកិច្ចសន្យាឡើយ។



ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

Scanned with CamScanner

27/2

## ការអះអាងរបស់គូភាគី

ដើមចោទឈ្មោះ [redacted] សុជាតា បានថ្លែងហេតុថា: ខ្លួនប្តឹងឧទ្ធរណ៍ដើម្បីទាមទារសំណងខូចខាត និងជំងឺចិត្តបន្ថែមទៀត។ ខ្លួនបានហៅចុងចម្លើយឲ្យជួសជុលផ្ទះខ្លួន លុះដល់ពេលធ្វើចុងចម្លើយមិនបានធ្វើឲ្យត្រឹមត្រូវលក្ខណៈបច្ចេកទេសទេ បានធ្វើឲ្យខូចខាតសម្ភារៈរបស់ខ្លួន ដូចជាក្បឿង និងសម្ភារៈផ្សេងៗមួយចំនួនទៀត។ ការធ្វើឲ្យខូចខាតនេះ ខ្លួនបានប្តឹងទៅប៉ូលីស ពេលនោះប៉ូលីសបានហៅទៅដោះស្រាយភាគីចុងចម្លើយបានយល់ព្រមសងឲ្យខ្លួនតាមការទាមទារ តែក្រោយមកក៏និយាយថា អត់ព្រមសងវិញ ហើយថែមទាំងប្រើពាក្យបញ្ឆោះបន្សោកឲ្យខ្លួនថា បើចង់បានសំណងឲ្យខ្លួនកើបកំទេចក្បឿងថ្លឹងទៅ។ នៅពេលនេះខ្លួនសំណូមពរសុំទាមទារសំណងខូចខាតចំនួន៨៧៦២០បាត ឈ្នួលជាងចំនួន២០០$ និងជម្ងឺចិត្តចំនួន១០លានរៀល។

ចុងចម្លើយឈ្មោះ [redacted] សំអៀន បានថ្លែងហេតុថា: ខ្លួនបានទទួលជួសជុលផ្ទះឲ្យដើមចោទប្រាកដមែន។ តែការជួសជុលអត់បានធ្វើឲ្យខូចខាតដូចការប្តឹងរបស់ដើមចោទនោះទេ ការខូចខាតមានមែនតែអត់ច្រើនទេ គឺមានតែបន្តិចបន្តួចខ្លួនទទួលស្គាល់ ហើយសុខចិត្តសងវិញតាមការជាក់ស្តែង។ នៅពេលនេះ ខ្លួនសំណូមពរសុំសងទៅដើមចោទ នូវអ្វីដែលខ្លួនបានធ្វើខូចជាក់ស្តែង តែអ្វីដែលលើសខ្លួនសុំមិនសងដាច់ខាត។

## សំអាងហេតុ

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦-០២-២០១២ របស់ឈ្មោះ [redacted] សុជាតា និងចុះថ្ងៃទី០២-០២-២០១២ របស់ឈ្មោះ [redacted] សំអៀន ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ដើមចោទ និងដើមបណ្តឹងឧទ្ធរណ៍បានធ្វើសេចក្តីថ្លែងហេតុថា ចុងចម្លើយបានទទួលការជួសជុលធ្វើដំបូលផ្ទះរបស់ខ្លួន ហើយត្រូវកូនជាងចុងម្លើយ ធ្វើឲ្យខូចដំបូលផ្ទះដែលការខូចខាតនេះមានចំនួន ៨៧៦២០បាត និង២០០$។ កាលនៅប៉ូលីសបានធ្វើការសម្រុះសម្រួលខ្លួនព្រមទទួលយកចំនួន១៨៧២០ បាត តែចុងចម្លើយដល់ពេលកំណត់ត្រូវសងពុំព្រមសង ទើបខ្លួនប្តឹងមកតុលាការដោយទាមទារចំនួន ៨៧៦២០បាត និង ២០០$ ព្រមទាំងជម្ងឺចិត្តចំនួន១០លានរៀល។

៣-ចុងចម្លើយបានធ្វើសេចក្តីថ្លែងហេតុថា នៅថ្ងៃកើតហេតុខ្លួនមិនបានទៅឲ្យប្រពន្ធនៅមើល។ នៅថ្ងៃនោះមានមេឃភ្លៀង ខ្លួនមិនឲ្យកូនជាងធ្វើទេ តែដើមចោទថាឲ្យធ្វើទៅព្រោះគាត់ជាម្ចាស់ផ្ទះ។ ខ្លួនទទួលស្គាល់ការខូចខាត តែសុំឲ្យម្ចាស់ផ្ទះបង្ហាញភស្តុតាង។

៤-តាមការយល់ឃើញខាង គឺចុងចម្លើយពិតជាមានកំហុសក្នុងការបំពេញការងាររបស់ខ្លួន ដែលធ្វើឲ្យដើមចោទទទួលសងនូវការខូចខាត។

27

៥-សាលក្រមរដ្ឋប្បវេណីលេខ:០២(ខ) ចុះថ្ងៃទី២៥-០១-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចត្រឹមត្រូវតាមច្បាប់ហើយ លើកលែងតែចំណុចទី១ ត្រង់ឲ្យចុងចម្លើយសងប្រាក់ការខូចខាត ត្រូវសម្រេចឡើងវិញ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ក/-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦-០២-២០១២របស់ឈ្មោះ [redacted] សុជាតា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

ខ/-ច្រានពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២-០២-២០១២ របស់ឈ្មោះ [redacted] សំអៀន ចោលជាអសារបង់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ:០២(ខ) ចុះថ្ងៃទី២៥-០១-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ លើកលែងតែចំណុចទី១ ត្រង់សំណងការខូចខាតចំនួន១៨៧២០បាត ត្រូវកែប្រែទៅជាចំនួន៨៧៦២០បាត និង ២០០ដុល្លាអាមេរិក ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល។

៣-ប្រាក់ប្រដាក់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២១-០២-២០១៣ បើកផ្លូវប្តឹងសាទុក្ខរយៈពេលមួយខែគិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សា

ហត្ថលេខា [redacted]

-បានចម្លងត្រឹមត្រូវតាមច្បាប់ដើម-

ភ្នំពេញ, ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]



Scanned with CamScanner